រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
PHNOM PENH WATER SUPPLY AUTHORITY

# គម្រោងពង្រីកប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតនិរោធ (ដំណាក់កាលទី៣)
# របស់
# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

---

## ព័ត៌មានអំពីគម្រោង

---

### ១. សាវតាគម្រោង

- **ម្ចាស់គម្រោង៖** រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- **ម្ចាស់កម្ចីហិរញ្ញប្បទាន៖** កម្ចីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
- **ប្រភេទគម្រោង៖** គម្រោងអភិវឌ្ឍន៍របស់រដ្ឋ
- **សមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតដំណាក់កាលទី៣៖** ២០០.០០០ ម៣/ថ្ងៃ
- **ទំហំផ្ទៃដីពង្រីករបស់អាងប្រព្រឹត្តកម្មទឹកស្អាត៖** ៥,២០ ហិកតា
- **តំបន់សេវាកម្ម៖** ៧ ខណ្ឌ ក្នុងរាជធានីភ្នំពេញ និង ៣ ស្រុក/ក្រុង ក្នុងខេត្តកណ្ដាល
- **ប្រវែងបណ្ដាញបំពង់ទុយោមេនាំទឹកស្អាត៖** ៨,៥២ គីឡូម៉ែត្រ
- **ប្រវែងបណ្ដាញបំពង់ចែកចាយទឹកស្អាត៖** ១.៣២០ គីឡូម៉ែត្រ
- **រយៈពេលសាងសង់៖** ឆ្នាំ ២០២៦-ឆ្នាំ ២០៣០

### ២. ទីតាំងគម្រោង

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងធ្វើការពង្រីកប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតនិរោធ (ដំណាក់កាលទី៣) ដែលមានទីតាំងស្ថិតនៅក្នុងរោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធ ក្នុងភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ សម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់តំបន់សេវាកម្មនៅក្នុងរាជធានីភ្នំពេញ ដែលមានដូចជា ខណ្ឌសែនសុខ ខណ្ឌទួលគោក ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌច្បារអំពៅ។ ដោយឡែកសម្រាប់នៅក្នុងខេត្តកណ្ដាលវិញមាន ក្រុងតាខ្មៅ ស្រុកកណ្ដាលស្ទឹង និងស្រុកស្អាង។




ផែនទី ១៖ បង្ហាញពីទីតាំងគម្រោងទាំងមូល

## ៣. ហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់តំបន់សិក្សា

គម្រោងពង្រីកប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតនិរោធ (ដំណាក់កាលទី៣) បានធ្វើបច្ចុប្បន្នភាព និងកែសម្រួលនូវផ្លូវសម្រាប់អូសបណ្ដាញទឹកស្អាត (Routes) ដើម្បីបញ្ចប់ការសិក្សាលើគម្រោងនេះ។ ការកែសម្រួលផ្លូវសម្រាប់អូសបណ្ដាញទឹកស្អាត (Routes) គឺផ្ដោតជាសំខាន់ក្នុងខណ្ឌខណ្ឌច្បារអំពៅ ដែលមានសង្កាត់ពីរគឺសង្កាត់និរោធ និងសង្កាត់វាលស្បូវ ដូចមានបង្ហាញក្នុងផែនទីខាងក្រោម៖




រូបភាព ១៖ បង្ហាញពីការកែសម្រួលផ្លូវសម្រាប់អូសបណ្ដាញទឹកស្អាត (Routes) (ក្នុងសង្កាត់សង្កាត់និរោធ និងសង្កាត់វាលស្បូវ)

## ៤. ការជួបពិគ្រោះយោបល់ជាសាធារណៈ ឬជនពាក់ព័ន្ធ

ក្រុមសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនឹងធ្វើការជួបប្រជុំពិគ្រោះយោបល់ជាសាធារណៈ ជាលើកទី២ សម្រាប់ការសិក្សាបរិស្ថាន និងសង្គម សម្រាប់គម្រោង ដោយផ្ដោតលើការកែសម្រួលផ្លូវសម្រាប់អូសបណ្ដាញទឹកស្អាត (Routes) គឺផ្ដោតជាសំខាន់ក្នុងខណ្ឌខណ្ឌច្បារអំពៅ ដែលមានសង្កាត់ពីរគឺសង្កាត់និរោធ និងសង្កាត់វាលស្បូវ។ សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនេះនឹងមានការចូលរួមពី អ្នកតំណាង អាជ្ញាធរមូលដ្ឋានភូមិ-ឃុំពាក់ព័ន្ធ និងប្រជាពលរដ្ឋរស់នៅក្បែរតាមបណ្ដាញខ្សែរអូសបណ្ដាញទឹកស្អាត (Routes) ដែលអាចទទួលរងផលប៉ះពាល់ពីសកម្មភាពគម្រោង។ ការជួបប្រជុំពិគ្រោះយោបល់ធ្វើឡើងក្នុងមានគោលបំណងដូចខាងក្រោម៖

- បង្ហាញពីលទ្ធផលនៃការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១
- ពិភាក្សាពីហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានឡើងចេញពីកែសម្រួលផ្លូវសម្រាប់អូសបណ្ដាញទឹកស្អាត (Routes)
- ដើម្បីប្រមូលធាតុចូល គំនិតយោបល់ ឬក៏អនុសាសន៍ល្អៗបន្ថែមទៀតពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ទៅលើទិដ្ឋភាពផ្សេងៗ និងបញ្ហាមួយចំនួនដែលទាក់ទងជាមួយនឹងសកម្មភាពគម្រោង។

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២ នេះនឹងត្រូវធ្វើឡើងនៅចន្លោះថ្ងៃទី៧-១១ ខែមេសា ឆ្នាំ២០២៥។ កាលវិភាគសម្រាប់កិច្ចប្រជុំនេះអាចមានការកែប្រែ តាមការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន។